

# ប្រាសាទព្រៃគុក

តាមរយៈការស្រាវជ្រាវកន្លងមកបង្ហាញថា នៅទឹកដីខេត្តព្រះវិហារសព្វថ្ងៃ មាននៅសល់តឹកតាងប្រាសាទសម័យមុនអង្គរតិចតួចខ្លាំងណាស់ ហើយក្នុងនោះប្រាសាទដែលគេស្គាល់ច្រើនជាងគេគឺ ប្រាសាទត្រពាំងគុក ដែលជាស្ថាបត្យកម្មមានសំណង់គក់គ្រឹះដូចប្រាសាទអាស្រមមហាឥសី និងភ្នំដាជាដើម។ ក្រៅពីប្រាសាទនេះ មានប្រាសាទមួយទៀត ដែលអ្នកស្រាវជ្រាវ មកពីអឺរ៉ុបកត់សម្គាល់ និងធ្លាប់សិក្សាច្រើនមកហើយ ពោល គឺ ប្រាសាទព្រៃគុក។ ប្រាសាទនេះ ស្ថិតនៅក្នុងភូមិប្រើសក្អក ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ ដែលជាតំបន់សម្បូណ៌ដោយជនជាតិកួយរស់នៅសព្វថ្ងៃ។

នៅក្នុងឆ្នាំ១៨៧៩ លោកបណ្ឌិត Harmand, J. បានចេញផ្សាយសៀវភៅមួយមានចំណងជា "Notes de voyage en Indo-Chine, Les Kouys, Ponthey Kakeh. Considération sur les monuments dits Khmer" ដែលជាឯកសារគោលមួយដែលបានរៀបរាប់អំពីប្រាសាទព្រៃគុកនេះមុនគេ។ ក្រោយមកមកដល់ស.វ.ទី២០ អ្នកស្រាវជ្រាវល្បីឈ្មោះចំនួន ៤ នាក់ បានសិក្សាអំពីប្រាសាទនេះជាបន្តបន្ទាប់ ពោល គឺលោក Étienne Aymonier, Lunet De Lajonquière, Henri Parmentier និង George Coedès។

ប្រាសាទព្រៃគុក មានលក្ខណៈពិសេសមួយបែបខុសពីប្រាសាទផ្សេងៗនៅស្រុកខ្មែរ ពោលគឺកាលពីស.វ.ទី៧-៨ គេបានឆ្លាក់ថ្មធម្មជាតិដែលមានស្ថិតនៅទីតាំងដើមស្រាប់

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

AMS KHMER CIVILIZATION

ឱ្យចេញជាក្បាច់មានខឿន ជាសារពើសូត្រ មានហោជាងដូចជើងក និងមានស្លាបសង្ខាង។ នៅចំកណ្ដាលសិល្បករឆ្លាក់រូបព្រះគណេស អង្គុយ ក្នុងកាយវិការពែនភ្នែកនៅលើជើងទម្រមួយ ដែលនៅខាងក្រោមទម្រគេឆ្លាក់ជារូបគ្រុឌលើកដៃត្រដាងស្លាបទ្រជើងទម្រ (រូបលេខ២១)។



រូបលេខ២១៖ រូបគ្រុឌទ្រទម្រព្រះគណេស

កាយវិការរបស់គ្រុឌរបៀបនេះ មានលក្ខណៈដូចនឹងគ្រុឌដែលគេឆ្លាក់ទ្រពីក្រោមវិមានអណ្ដែតដែលមាននៅតំបន់ប្រាសាទសំបូរព្រៃគុក។ ដោយឡែក នៅអមសងខាងព្រះគណេស គេបានឆ្លាក់រូបដំរីម្ខាងមួយៗ (រូបល២២)។



រូបលេខ២២៖ចម្លាក់ដំរីនៅអមព្រះគណេស

ទម្រង់ព្រះគណេសដែលឆ្លាក់ជាប់ថ្មធម្មជាតិរបៀបនេះ យើងកម្រឃើញមានក្នុងសិល្បៈខ្មែរនាស.វ.ទី៧-៨ណាស់ តែយើងធ្លាប់ឃើញគេឆ្លាក់នៅលើជញ្ជាំងថ្ម នៅតំបន់ភ្នំគូលែន ដូចឃើញមាននៅពើងត្បាល់ (រូបលេខ២៣) និងពើងគំនូរ ដែលគេឆ្លាក់ក្នុងកាយវិការឈរជិតព្រះឥសូរជាបិតារបស់ព្រះគណេស។ ជាទូទៅក្នុងសាសនាព្រាហ្មណ៍គេចាត់ទុកព្រះគណេស ជាទេពនៃបញ្ញា ចំណេះដឹង និងកំចាត់ឧបសគ្គ ឬអាចដាក់ជាឧបសគ្គ ដែលទម្រង់ជាទូទៅរបស់ទ្រង់ គឺមានពោះកំប៉ោងក្បាលជាសត្វដំរី និងមានយានជំនិះជាសត្វ

អត្ថបទដោយៈ ម៉ង់ វ៉ាលី



រូបលេខ៣៖ ចម្លាក់ព្រះគណេសនៅពើងឡាល់ ភ្នំគូលែន

កណ្ដារ ឬពេលខ្លះជិះលើសត្វដំរីក៏មាន។[១]

ក្រៅពីនេះ នៅខាងលើដំរីទាំងសងខាង យើងឃើញមានសិលាចារឹកជាភាសាសំស្ក្រឹត។ នៅផ្នែកខាងស្ដាំ មានចំនួន ២បន្ទាត់ និង នៅផ្នែកខាងឆ្វេងមានចំនួន ៤បន្ទាត់ដូចគ្នា។ សិលាចារឹកនេះ ចុះបញ្ជីលេខ K.358 ដែលធ្លាប់សិក្សាដោយលោក George Coedès ផ្សាយនៅក្នុងសៀវភៅ *Inscription du Cambodge* វគ្គទី៥ ដែលលោកគិតថាទំនងជាចារឹកនៅរវាងស.វ.ទី៧។[២] ចំណែក សេចក្ដីជាទូទៅនៃសិលាចារឹកនេះ រៀបរាប់ទាក់ទងនឹងការគោរពព្រះគណេស និងរឿងទេវកថាមួយចំនួនដែលទាក់ទងនឹងព្រះគណេស។[៣]

ក្រោយមក នៅរវាងស.វ.ទី១០ ដែលអាចស្ថិតនៅរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន គេបានសង់សំណង់ឥដ្ឋគ្របពីលើសំណង់ចាស់ ហើយនៅផ្នែកខាងកើតគេរៀបជាស៊ុមទ្វារ ជណ្ដើរ ធ្វើអំពីថ្មភក់ ព្រមទាំងតម្កល់រូបបដិមាតោពីរឈរអមសងខាងទ្វារចូលទៀតផង (រូបលេខ៤)។ ប្រពៃណីបែបសាងបន្ថែមបែប

[១] Roveda 2005: 174-177; Dimmit & Buitenen 1978: 179-185.

[២] Coedès 1953: 63.

[៣] Coedès 1953: 63; Dupont 1955: 110.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៤ៈ បដិមាគោនៅប្រាសាទព្រៃគុក

នេះ យើងតែងឃើញជារឿយៗនៅស.វ.ទី១០ ក្នុងរជ្ជកាលព្រះបាទពជេន្ទ្រវរ្ម័ន ជាក់ស្តែងដូចនៅក្រុមខាងជើង នៃតំបន់ប្រាសាទសំបូរព្រៃគុក ដែលមានសំណង់ជាច្រើនបានសាងសង់បន្ថែមនៅក្នុងរជ្ជកាលរបស់ទ្រង់។

ជារួមមក ប្រាសាទព្រៃគុក អាចចាត់ទុកបានថាជាសិល្បៈសម័យមុនអង្គរមួយដ៏សំខាន់ ដែលមានវត្តមាននៅលើទឹកដីខេត្តព្រះវិហារសព្វថ្ងៃ និងជាទីស្ថានសក្ការបូជាព្រះគណេសមួយនៅក្នុងស្ថាបត្យកម្មខ្មែរ។

អត្ថបទដោយៈ ម៉ង់ រ៉ាលី

# ឯកសារយោង

**Aymonier, Etienne**
1900, *Le Cambodge: Le Royaum Actuel*. Paris. Ernest Leroux.
**Coedès, George**
1953, *Inscription du Cambodge*, Vol V, Hanoi
**Dupont, Pierre**
1955, *La statuaire préangkorienne*, Paris
**Dimmit, Cornelia & Buitenen, J.A.B**
1978, Classical Hindu Mythology, USA

**Lunet de Lajonquière**
1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris
**Parmentier, Henri**
1927, *L'Art Khmer Primitif*. Paris: G. Van Oest.
1935, Complément à l'inventaire descriptive des monuments du Cambodge, *BEFEO*, 35, Paris
**Roveda, Victorio**
2005, "*Image of the gods*", Bangkok

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION